# ការឃ្លាំមើល ព្រៃឈើនៅក្នុង ដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរកា និងសង្ឃរុក្ខាវ៉ន

### របាយការណ៍ឃ្លាំមើលលើកទី៤

**១២០,៨២៩**
ហិកតា នៃគម្របព្រៃឈើ

**១.៤%**
នៃតំបន់សរុប

**១៦%**
ការបាត់បង់កើនឡើង

កម្ពុជាបានប្រឈមមុខនឹងបញ្ហាបរិស្ថានដ៏សំខាន់ក្នុងឆ្នាំ២០២៣ ដោយមានការបាត់បង់គម្របព្រៃឈើចំនួន ១២០,៨២៩ ហិកតា ដែលស្មើនឹង ១.៤% នៃផ្ទៃដីសរុបរបស់ខ្លួន និងមានចំនួន ៧១.២ លានតោននៃកាបូនឌីអុកស៊ីត ត្រូវបានបញ្ចេញទៅក្នុងបរិយាកាស ដែលកើតឡើងដោយសារការបាត់បង់គម្របដើមឈើ។ គួរកត់សម្គាល់ថាចំនួន ៤០% នៃការបាត់បង់នេះបានកើតឡើងនៅក្នុងតំបន់ការពារ ពោលគឺកើនឡើងចំនួន ១៦% បើធៀបនឹងឆ្នាំមុន។ ជាក់ស្តែង ដែនជម្រកសត្វព្រៃព្រៃឡង់ បានបាត់បង់ចំនួន ៩,៥៣២ ហិកតា (កើនឡើងចំនួន ១០.៣%) ដែនជម្រកសត្វព្រៃ ព្រះរកា បានជួបការបាត់បង់ចំនួន ៥៧៥ ហិកតា (កើនឡើងចំនួន ៣៥%) និងដែនជម្រកសត្វព្រៃ សង្ឃរុក្ខាវ៉ន ត្រូវបានកត់ត្រាពីការបាត់បង់ចំនួន ៤២ ហិកតា (កើនឡើងចំនួន ៥០%)។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ គំនិតផ្តួចផ្តើមរបស់គម្រោង ការចូលរួមរបស់ពលរដ្ឋដើម្បី យុត្តិធម៌បរិស្ថាន សម្រាប់ទាំងអស់គ្នា (CEEJA) ត្រូវបានចាប់ផ្តើម ដោយផ្តោតលើដែនជម្រកសត្វព្រៃទាំងបីនេះ។ CEEJA ប្រើទាំងការឃ្លាំមើលដោយសហគមន៍មូលដ្ឋាន និងបច្ចេកវិទ្យាផ្កាយរណបកម្រិតខ្ពស់ ដើម្បីវាយតម្លៃ និងបង្កើនប្រសិទ្ធភាពនៃការការពារព្រៃឈើជាក់ស្តែង និងប្រយុទ្ធប្រឆាំងនឹងការបាត់បង់គម្របដើមឈើ។

ទោះបីជាមានការខិតខំប្រឹងប្រែងអភិរក្សក៏ដោយ ក៏ការកាប់ឈើខុសច្បាប់នៅតែជាបញ្ហាបន្តកើតមាននៅក្នុងតំបន់ការពារជាច្រើនរបស់កម្ពុជា។ ផ្លូវថ្មីដែលសម្រួលដល់ការកាប់ឈើត្រូវបានគេរកឃើញនៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ ដែលបង្ហាញដោយរូបភាពផ្កាយរណប។

## ផ្លូវថ្មីចំនួនពីរ ដែលមានប្រវែង ១២គីឡូម៉ែត្រ មានប្រភពចេញពីក្រុមហ៊ុនសម្បទាន Think Biotech។

សហគមន៍ និងអ្នកជំនាញព្រមានថា ផ្លូវថ្មីទាំងនេះ ទំនងជា នឹងធ្វើឱ្យសកម្មភាពកាប់ឈើកាន់តែខ្លាំងក្លាឡើងនៅក្នុងតំបន់ ដែលនាំឱ្យមានការពន្លឿនការកាប់ព្រៃឈើ និងការរិចរិលព្រៃឈើនៅក្នុងតំបន់ការពារដែនជម្រកសត្វព្រៃ។ លើសពីនេះ ប្រតិបត្តិការរុករករ៉ែបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ជាពិសេសនៅតំបន់ព្រៃឡង់ ដែលក្រុមហ៊ុន Late Cheng Mining Development បានទទួលអាជ្ញាប័ណ្ណរុករក និងទាញយករ៉ែមាស។ សកម្មភាពទាំងនេះបាននាំទៅដល់ការឈូសឆាយព្រៃ ការបែកខ្ញែកទីជម្រក និងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថាន ពីការប្រើប្រាស់សារធាតុស្យានីត (Cyanide) ក្នុងការទាញយកមាស។

↓ **រូបភាពទី១**
សហគមន៍ខេត្តស្ទឹងត្រែង រាយការណ៍ពីការឈូសឆាយព្រៃមួយកន្លែងនៅក្នុងដីសម្បទានមួយ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣។



សហគមន៍មូលដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងការឃ្លាំមើល និងការពារតំបន់ទាំងនេះ។
**បណ្តាញសហគមន៍ព្រៃឡង់ (PLCN)** បានកត់ត្រាទិន្នន័យចំនួន ៨,៤២៨ ក្នុងឆ្នាំ២០២៣។

**១៣០% កើនឡើងពីឆ្នាំមុន**

មានចំនួន ៧២% នៃទិន្នន័យដែលទាក់ទងនឹងធនធានព្រៃឈើ និងចំនួន ២៤% ដែលកត់ត្រាសកម្មភាពខុសច្បាប់។ ដូចគ្នានេះដែរ **បណ្តាញសហគមន៍ព្រៃព្រះរកា (PFCN)** បានរាយការណ៍ចំនួន ៧៣៤ ទិន្នន័យនៅក្នុងឆ្នាំ២០២៣។

**១២៣% កើនឡើងពីឆ្នាំមុន**

មានចំនួន ៦២% ទាក់ទងនឹងជីវចម្រុះ និងចំនួន ២៤% រាយការណ៍ពីសកម្មភាពខុសច្បាប់។



↑ **រូបភាពទី២**
សហគមន៍នៃដែនជម្រកសត្វព្រៃព្រះរការក្សាទុកកូនឈើប្រភេទជិតផុតពូជពីតំបន់ងាយរងគ្រោះដើម្បីដាំវាឡើងវិញ។

ទីបំផុត **សង្ឃសហគមន៍រុក្ខាវ៉ន (MCF)** នៅដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ៉ន បានចងក្រងចំនួន ៦២ទិន្នន័យ។

**១៧០% កើនឡើងពីឆ្នាំ២០២២**

មានចំនួន ៧៩% ដែលបានរាយការណ៍ពីការចងក្រងទិន្នន័យពីធនធានដ៏មានតម្លៃ និងមានតិចជាងចំនួន ១១% នៃទិន្នន័យដែលរាយការណ៍ពីសកម្មភាពខុសច្បាប់ផ្សេងៗ។ កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ទាំងនេះផ្តល់នូវទិន្នន័យតាមភូមិសាស្ត្រជាក់ស្តែងដែលមានតម្លៃមិនអាចកាត់ថ្លៃបាន ក្នុងការបំពេញបន្ថែមដោយការឃ្លាំមើលពីផ្កាយរណប និងផ្តល់ភស្តុតាងជាទម្រង់រូបថត និងព័ត៌មានលម្អិតប្រកបដោយគុណភាព។ ភ័ស្តុតាងនេះជួយបង្កើនការយល់ដឹងរបស់យើងអំពីស្ថានភាពជាក់ស្តែង និងបន្ថែមស្រទាប់ព័ត៌មានទៅក្នុងទិន្នន័យផ្កាយរណប ដោយបង្ហាញពីសកម្មភាពខុសច្បាប់ និងទីកន្លែងដែលពោរពេញទៅដោយជីវចម្រុះនៅក្នុងតំបន់ការពារ។

**កិច្ចព្រមព្រៀង ក្របខណ្ឌជីវចម្រុះសាកល (GBF) ទីក្រុង Kunming-Montreal** ដែលបានអនុម័តនៅខែធ្នូ ឆ្នាំ២០២២ បានកំណត់គោលដៅប្រកបដោយមហិច្ឆិតាសម្រាប់ការអភិរក្សជីវចម្រុះ រួមទាំងការការពារឱ្យបាន ៣០% នៃផ្ទៃដី និងសមុទ្រនៅឆ្នាំ២០៣០។ ទោះជាយ៉ាងនេះក៏ដោយ ស្ថានភាពនៅកម្ពុជាបង្ហាញពីបញ្ហាប្រឈមជាច្រើនក្នុងការអនុវត្តគោលដៅទាំងនេះនៅកម្រិតមូលដ្ឋាន។ ការសង្កត់ធ្ងន់របស់ក្របខណ្ឌស្តីពីការទទួលស្គាល់សិទ្ធិ និងចំណេះដឹងរបស់ជនជាតិដើមភាគតិច ស្របតាមការងាររបស់សហគមន៍មូលដ្ឋានក្នុងប្រទេសកម្ពុជា ប៉ុន្តែការគំរាមកំហែងពីការកាប់ឈើខុសច្បាប់ ការជីកយករ៉ែ និងកង្វះការគាំទ្រពីរដ្ឋាភិបាល បង្កជាឧបសគ្គយ៉ាងខ្លាំងក្នុងការសម្រេចបាននូវគោលដៅសកលទាំងនេះ។
កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍មូលដ្ឋានក្នុងប្រទេសកម្ពុជាបង្ហាញពីសារៈសំខាន់ដែលមិនអាចខ្វះបាន នៃការចូលរួមនៅមូលដ្ឋានក្នុងការសម្រេចបាននូវគោលដៅជីវចម្រុះជាសកល។ ការងារការឃ្លាំមើល និងការពារព្រៃឈើដោយផ្ទាល់របស់ពួកគេ រួមចំណែកដល់គោលដៅដែលបានកំណត់ដោយក្របខ័ណ្ឌទីក្រុង Kunming-Montreal ។ ក្នុងចំណោមសកម្មភាពផ្សេងៗទៀត កិច្ចខិតខំប្រឹងប្រែងទាំងនេះស្របតាមគោលដៅទី៣ (ការពារឱ្យបាន ៣០% នៃផ្ទៃដី និងសមុទ្រ) គោលដៅទី៤ (វិធានការគ្រប់គ្រងជាបន្ទាន់ដើម្បីបញ្ឈប់ការផុតពូជ និងរក្សាការប្រែប្រួលជីវសាស្ត្រដែលបណ្តាលមកពីមនុស្ស) គោលដៅទី២១ (ធានាថាទិន្នន័យដែលមានល្អបំផុតគឺ អាចចូលប្រើប្រាស់បានចំពោះអ្នកធ្វើសេចក្តីសម្រេចចិត្ត ដើម្បីណែនាំអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព) ហើយសំខាន់បំផុត គោលដៅទី២២ (ធានាឱ្យមានការចូលរួមប្រកបដោយសមធម៌ និងប្រសិទ្ធភាពនៃ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងជីវៈចម្រុះ)។

ទោះជាយ៉ាងណាក៏ដោយ សហគមន៍ទាំងនេះប្រឈមមុខនឹងបញ្ហាប្រឈមជាបន្តបន្ទាប់ រួមទាំងការយាយីពីអាជ្ញាធរ និងការរឹតត្បិតលើសកម្មភាពអភិរក្សរបស់ពួកគេ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងស្របតាមគោលដៅជីវចម្រុះសកល សហគមន៍ជំរុញឱ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការជាក់លាក់ រួមមាន៖

**និងគាំទ្រកិច្ចខិតខំប្រឹងប្រែងអភិរក្សដែលធ្វើឡើងដោយសហគមន៍ ការអនុវត្តច្បាប់បរិស្ថានដែលមានស្រាប់ ការបញ្ឈប់សកម្មភាពកាប់ឈើខុសច្បាប់ និងការជីកយករ៉ែនៅក្នុងតំបន់ការពារ និងធានានូវដំណើរការក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយតម្លាភាព សម្រាប់ការគ្រប់គ្រងព្រៃឈើ។**